# ឯកឧត្តម សូរ យុន សូត្រមន្តនៅក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍









ក្នុងឱកាសចូលរួមទទួលអំណរសាទរ បុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិឆ្នាំឆ្លូវ ឯកស័ក ព.ស ២៥៥៣ គ្រឹះសករាជ២០០៩ ដែលនឹងឈានចូលមកដល់ក្នុងពេលដ៏ខ្លីខាងមុខនេះ នៅក្រសួងប្រៃសណីយ៍ និង ទូរគម នាគមន៍ **ឯកឧត្តម សូរ យុន** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ និងលោកជំទាវ រួមជាមួយ ឯកឧត្តមរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ចំណុះក្រសួងប្រៃសណីយ៍ និង ទូរកមនាគមន៍ បាននិមន្តព្រះសង្ឃចំនួន៧អង្គ មកពីវត្តនានា ក្នុងរាជធានីភ្នំពេញ សូត្រមន្តចំរើនព្រះបរិត ជាកិច្ចទទួលអំណរសាទរទេព្តាឆ្នាំថ្មី **ព្រះនាម រក្សាទេវី** ដែលឈានចូលមកដល់ ដើម្បីគ្រប់គ្រងថែរក្សា ការពារ ដល់ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ក៏ដូចជាប្រជាពលរដ្ឋទូទាំងប្រទេស បានសេចក្តីសុខក្សេនក្សាន្ត និង ជំរះរាល់ឧបទ្រុបចង្រៃ ក្នុងឆ្នាំចាស់ចេញ និងទទួលយកពរជ័យសិរីសួស្តីក្នុងឆ្នាំថ្មី សំរាប់បំរើការងារក្នុងវិស័យ ប្រៃសណីយ៍ និង ទូរគមនាគមន៍ និងរួម ចំណែកអភិវឌ្ឍន៍ប្រទេសជាតិ អោយសំបូររុងរឿង ស្របតាមគោលនយោបាយ

របស់រាជរដ្ឋាភិបាល អាណត្តិទី៤ ក្រោមការដឹកនាំដ៏ឈ្លាសវៃ របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ។ **ឯកឧត្តម** ក៏បានរាប់បានដល់ព្រះសង្ឃ ដើម្បីឧទ្ទិសមគ្គផលកុសល ផលបុណ្យ ជូនចំពោះមាតាបិតា ជីដូនជីតាញាតិការ ទាំង៧សណ្តាន ដែលបានចែកឋានទៅកាន់បរិលោក ទោះបីយូរមកហើយក្តី ថ្មីៗក្តី សូមទទួលបាននូវ សេចក្តី សុខ ក្នុងឋានសុគតិភព កុំបីឃ្លាងឃ្លាតឡើយ ក្នុងឱកាសទទួលអំណរឆ្នាំថ្មី ។

បន្ទាប់មក **ឯកឧត្តម សូរ ឃុន** បានជួបសំណេះសំណាល ជាមួយមន្ត្រីចូលនិវត្តន៍ ដោយបានថ្លែង អំណរគុណយ៉ាងជ្រាវជ្រៅ ចំពោះមន្ត្រីចូលនិវត្តន៍ទាំងអស់ ដែលកន្លងមកបានខិតខំប្រឹងប្រែងបំពេញការងារ ជូនក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ អោយដំណើរការរីកចំរើន ។ **ឯកឧត្តមរដ្ឋមន្ត្រី** មាន ប្រសាសន៍បន្តទៀតថា ទោះបីមន្ត្រីទាំងអស់បានចូលនិវត្តន៍ក្តី ក៏ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ នៅតែស្រលាញ់រាប់អានគ្នាទៅវិញទៅមក និងជួយគ្នាគ្រប់កាលៈទេសៈ ។ ក្នុងពិធីនេះ **ឯកឧត្តម សូរ ឃុន** បានប្រគល់គ្រឿង ឥស្សរិយយសការងារ និង ឧបត្ថម្ភថវិកា របស់សមាគមបុគ្គលិក ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ដល់មន្ត្រីចូលនិវត្តន៍ ទាំង២៤ខេត្ត-ក្រុង ចំនួន១៦១នាក់ ក្នុងម្នាក់ៗទទួលបានថវិកា ៨0,000រៀល(៨ម៉ឺនរៀល) ដោយឡែក មន្ត្រីចូលនិវត្តន៍ ចូលរួមក្នុងពិធី សូត្រមន្តនេះ បានទទួលថវិកាបន្ថែម២0,000រៀល(២ម៉ឺនរៀល)ទៀត ។ ដើម្បីអបអរសាទរ បុណ្យចូល ឆ្នាំថ្មីប្រពៃណីយ៍ជាតិខាងមុខនេះ **ឯកឧត្តម សូរ ឃុន** បានអញ្ជើញក្រុមសិល្បៈរបាំត្រុត មកសំដែងផងដែរ ។



